



អត្ថបទលោក វ៉ោយ វិបុល សមាជិកគណៈកម្មការស្រាវជ្រាវហោរាសាស្ត្រ
និងទំនៀមទម្លាប់នៃគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ និងអន្តរជាតិ

# ការសាងព្រះហស្ដព្រះបាទជ័យវរ្ម័នទី ៧ ព្រះមហាវីរក្សត្រ គប្បីសាងក្នុងកិរិយាបថបែបណា?

ក្រោយពីទទួលរងនូវសង្គ្រាមកាប់សំលាប់ ទុក្ខវិនាស ព្រាត់ប្រាស់ និរាសចាកក្រុមគ្រួសាររួចមក ប្រទេស និងប្រជារាស្ត្រ បានធ្លាក់អាប់ឱនកេរ្តិ៍ឈ្មោះយ៉ាងខ្លាំង ពិសេសក្នុងរបបប្រល័យពូជសាសន៍ខ្មែរក្រហម ។ បញ្ហាទាំងនេះធ្វើឱ្យខ្មែរបាត់បង់ស្មារតី បាត់បង់ទំនុកចិត្តគ្នា បាត់បង់ការទទួលខុសត្រូវ មានចិត្តរវើរវាយ មិននឹងន់ ។ លើសពីនេះទៀតខ្មែរស្រេកឃ្លាននូវសន្តិភាព សេចក្តីថ្លៃថ្នូរ និងភាព សំបូររុងរឿងឡើងវិញ។ មានខ្មែរអ្នកស្នេហាជាតិជាច្រើន តែងនឹកស្រមៃដល់សម័យមហានគរ ដែលស្ថិតក្រោមព្រះរាជកិច្ចដឹកនាំដ៏ឈ្លាសវៃអង់អាចក្លាហានរបស់ព្រះបាទជ័យវរ្ម័នទី ៧ជាគំរូ ។ តាមរយៈ សិលាចារឹក និងប្រវត្តិសាស្ត្រ បានបញ្ជាក់ប្រាប់ថា ព្រះបាទជ័យវរ្ម័នទី ៧ ព្រះអង្គជាព្រះមហាក្សត្រដ៏អស្ចារ្យរបស់ខ្មែរមានព្រះប្រាជ្ញាញាណវាងវៃក្នុងការគ្រប់គ្រង និងកសាងប្រទេសទ្រង់ប្រតិបត្តិតាមទសពិធរាជធម៌យ៉ាងល្អបរិសុទ្ធ ឥតមានលំអៀងឡើយ ។ ដោយគុណធម៌ សីលធម៌ និងអបចាយនធម៌ដ៏ប្រពៃនេះធ្វើឱ្យអាណាប្រជានុរាស្ត្រ មិនអាចបំភ្លេចបាននូវមហាគុណូបការៈដ៏ធំធេងនោះឡើយ ទើបសាងឡើងនូវព្រះរូបបដិមារបស់ព្រះអង្គ ទុកគោរពបូជាតរៀងមក ។ ដោយសារប្រទេសកម្ពុជា បានឆ្លងកាត់សង្គ្រាមជាច្រើនសម័យកាល ធ្វើឱ្យបាត់បង់ប្រវត្តិសាស្ត្រអំពីរឿងរ៉ាវនៃព្រះហស្ថ និង ព្រះសិរសារបស់ព្រះអង្គ ដែលត្រូវបាត់ និង ផតមួយដុំនោះ ។

រឿងបាត់ព្រះហស្ត និងផតព្រះសិរសា មួយជុំរបស់ព្រះបាទជ័យវរ្ម័នទី ៧នេះ ធ្វើឱ្យមានមតិចចាមអារ៉ាម មិនជាផ្លូវការចោទឡើងផ្សេងៗគ្នា គឺមតិខ្លះថា បាត់ព្រះហស្តដោយសារប្រទេសជិតខាងលួចយកទៅ ដើម្បីលាក់ភស្តុតាងក្នុងគោលបំណងអ្វីមួយ...បែកព្រះសិរសាដោយសារពួកបច្ចាមិត្តដែលស្អប់ព្រះអង្គកាលនៅខ្លាំងពូកែ ។ មតិខ្លះថា បាត់ព្រះហស្ត និងព្រះសិរសារបស់ព្រះបាទជ័យវរ្ម័នទី ៧ សុទ្ធតែជាវត្ថុមានតម្លៃទើបគេលួចយកទៅនិងវាយបំបែកមើលក្រែងមានមាសពេជ្រ ឬវត្ថុមានតម្លៃនៅក្នុងព្រះសិរសានោះ ។ មតិខ្លះថា បរមរូបព្រះបាទជ័យវរ្ម័នទី ៧នេះ គេសាងឡើងដោយគ្មានព្រះហស្ត និងធ្វើឱ្យមានស្នាមបែកព្រះសិរសាដូច្នេះតែម្តង ព្រោះអ្នកកសាងចង់បង្ហាញប្រាប់ថាមហានគរដ៏ខ្លាំងពូកែ ដែលគ្រប់គ្រងដោយព្រះបាទជ័យវរ្ម័នទី ៧នេះ ត្រូវធ្លាក់អន់ខ្សោយហើយដោយសេនាឆ្វេងស្តាំខ្លាំងៗរបស់ព្រះអង្គ ត្រូវបានបែកបាក់សាមគ្គីគ្នាអស់ ឯព្រះប្រាជ្ញាញាណដ៏វាងវៃរបស់ព្រះអង្គក៏ត្រូវដកហូតយកអស់ដែរ ដូច្នេះទើបស្ថាបត្យករសាងព្រះរូបនេះឡើង ដោយមានលក្ខណៈបាត់ព្រះហស្ត និងស្នាមផតព្រះសិរសាយ៉ាងនេះឯង ។ យោងតាមសភាពការណ៍ជាក់ស្តែង ដែលប្រទេស និងប្រជារាស្ត្រកម្ពុជាជួបតែសង្គ្រាម ទាស់ទែងគ្នាឥតឈប់ឈរ ទើបមានទស្សនៈខ្លះថា ដោយសារព្រះរូបព្រះបាទជ័យវរ្ម័នទី ៧សាងឡើងខ្វះលក្ខណៈដូច្នេះទើបបណ្តាលឱ្យប្រទេសកម្ពុជាជួបតែវិបត្តិសង្គ្រាមធ្លាក់អាប់ឱនកេរ្តិ៍ឈ្មោះជាប់ជានិច្ចយ៉ាងនេះ ។ ឥឡូវដើម្បីឱ្យស្រុកទេសបានសុខសន្តិភាពសំបូរសប្បាយ ថ្លៃថ្នូរ រុងរឿងតរៀងទៅ គួរសាងរូបបដិមាព្រះបាទជ័យវរ្ម័នទី ៧ឱ្យមានលក្ខណៈគ្រប់គ្រាន់ ដែលជានិមិត្តរូបទាញទឹកចិត្តខេមរបច្ឆាជនជំនាន់ក្រោយឱ្យមានក្តីសង្ឃឹម សុខសន្តិភាព សម្បូរណ៍សប្បាយ ថ្លៃថ្នូររុងរឿងឡើងវិញ ដូចសម័យមហានគរពីអតីតកាល ។ ទស្សនៈនេះសមហេតុសមផលម៉្យាងដែរ ព្រោះជាគំនិតចង់ឱ្យខ្មែរបានសុខសាន្ត ប៉ុន្តែដែលគួរឱ្យបារម្ភនោះ គឺការដាក់ព្រះហស្តរបស់ព្រះអង្គយ៉ាងដូចម្តេចដើម្បីឱ្យត្រូវតាមលំនាំព្រះរូបបដិមាដើមពិតប្រាកដ ។ រឿងនេះ គឺជាកង្វល់មួយដ៏លំបាកស្មុគស្មាញណាស់ក្នុងការធ្វើសេចក្តីសំរេចចិត្ត។ យើងដឹងហើយថា ព្រះបរមរូបព្រះបាទជ័យវរ្ម័នទី ៧ គឺជាព្រះមហាក្សត្ររបស់ខ្មែរ ប៉ុន្តែសៀមមានមហិច្ឆតាចង់យកធ្វើជាភស្តុតាងរបស់គេដែរ បញ្ហានេះធ្វើឱ្យយើងមានការរារែកក្នុងការសាង ព្រះបរមរូបបំពេញលក្ខណៈថ្វាយព្រះអង្គ ។

បច្ចុប្បន្ននៅសារមន្ទីរ និងកន្លែងផ្សេងទៀត ឃើញមានសាងព្រះបរមរូបព្រះបាទជ័យវរ្ម័នទី ៧ ដោយដាក់ឱ្យមានព្រះហស្ត និងបំពេញព្រះសិរសា ។ ចំពោះសណ្ឋានទ្រង់ទ្រាយនៃព្រះរូបរបស់ព្រះអង្គ ស្ថាបត្យករបានតាក់តែងឡើងដោយឥរិយាបថគង់ (អង្គុយ) ពែនភ្នែន ប៉ុន្តែព្រះហស្តប្រណម្យ (សំពះ)ទៅមុខទាំងពីរ។

ចំពោះឥរិយាបថបែបនេះមិនដឹងជាអស់លោកអ្នកស្រាវជ្រាវសំអាងទៅលើអ្វីទេ ឬមួយក៏ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំបាទសិក្សាតិចតួច មិនបានឃើញសព្វគ្រប់កន្លែងក៏មិនដឹង ។ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំបាទសូមព្រះរាជទានទោស និងសុំទោសទុកជាមុនដោយខ្លួនខ្ញុំជាកូនខ្មែរមួយរូបដែរ បើយល់មិនខុសទេ ការសំអាងខ្លះៗបានបង្ហាញថា ការសាងព្រះបរមរូបដោយគង់ពែនភ្នែន ហើយដាក់ព្រះហស្តប្រណម្យសំពះទៅមុខយ៉ាងនេះមិនត្រូវទេ។ ពីព្រោះអ្វី? ក្នុងឥរិយាបថទាំងឡាយមានដេក ដើរ ឈរ អង្គុយ ស៊ី ផឹក និយាយ ស្ដាប់ គិតទាំងអស់នេះបង្រួញមកនៅត្រឹម៤ គឺដេក ដើរ ឈរ និងអង្គុយ។

ដូចមានកំណាព្យទូន្មាននៅក្នុងវចនានុក្រមសម្ដេចព្រះសង្ឃរាជ ជោតញ្ញាណោ ជួន ណាត ទំព័រទី ១៧៧២ សរសេរថា "ឥរិយាបថបួនគួរជនប្រុងខ្លួន តាមសុជីវធម៌ត្រឹមត្រូវទៀងទាត់ បែបបទបវរ នឹងមានអំណរ មិននឹកស្ដាយក្រោយ"។ បណ្ដាឥរិយាបថទាំង ៦នេះ យើងគួរពិចារណាពិនិត្យមើលថា តើការប្រណម្យសំពះស្ថិតនៅក្នុងឥរិយាបថ ណា។ បើតាមទំនៀមទំលាប់ប្រពៃណីខ្មែរក៏ដូចជាប្រពៃណីព្រះពុទ្ធសាសនាដែរ សំពះ ឬប្រណម្យស្ថិតក្នុងឥរិយាបថពីរ គឺឈរ និងអង្គុយ ។

សំណួរ : តើឈរមានប៉ុន្មានយ៉ាង អ្វីខ្លះ? ចម្លើយ : ឈរមានច្រើនយ៉ាង គឺឈរត្រង់ខ្លួន ឈរអែនមកក្រោយ ឈរឱនទៅមុខ ឈរវៀចទៅឆ្វេង ឬទៅស្ដាំ ឈរបែរទៅមុខ ឈរបែរទៅក្រោយ ឈរបែរ ទៅឆ្វេង ឬទៅស្ដាំ ឈរក្រពាត់ដៃ ឈរឱបដៃដាក់លើថ្ងាស ពោះ ឈរជ្រែងហោប៉ៅ ឈរជ្រែងជើង ឈររាំ ឈរច្រៀង ឈរយំ ឈរសើច ឈរស្រងូតស្រងាត់ ។ល។ ឈរទាំងអស់នេះសរុបមក នៅត្រឹម២ គឺ ១-ឈរតាមធម្មតា, ២-ឈរដោយគោរព។

ទាំង ២យ៉ាងនេះ សូមលើកយកតែឈរដោយគោរពមួយមកបកស្រាយដូចតទៅ :

ឈរដោយគោរពមាន ៣យ៉ាងគឺ :

១-ឈរគោរពទង់ជាតិ ភ្នែកមើលទៅមុខត្រង់សំដៅទង់ជាតិ, ២-ឈរគោរពវិញ្ញាណក្ខន្ធ ឈរស្ងឹងស្ងាធ ភ្នែកសម្លឹងមកក្រោមបន្តិច និង៣-ឈរគោរពចំពោះបុព្វការីបុគ្គលមានមាតា បិតា គ្រូអាចារ្យ ព្រះឧបជ្ឈាយ៍ និងព្រះពុទ្ធបដិមា ។

សំណួរ : តើអង្គុយមានប៉ុន្មានយ៉ាង? អ្វីខ្លះ? ចម្លើយ : អង្គុយមានច្រើនយ៉ាងគឺ : អង្គុយច្រហោង អង្គុយលុតជង្គង់ អង្គុយបត់ជើង អង្គុយពែនភ្នែន អង្គុយបញ្ឈរជង្គង់ទាំងពីរ អង្គុយបញ្ឈរជង្គង់ម្ខាង ។ល។ អង្គុយទាំងអស់នេះសរុបមកនៅត្រឹម ២យ៉ាង គឺ : ១-អង្គុយធម្មតា, ២-អង្គុយដោយគោរព ។ ទាំង ២ យ៉ាងនេះសូមលើកយកតែអង្គុយដោយគោរពមួយមកបកស្រាយដូចតទៅ :

អង្គុយដោយគោរពមាន ៣យ៉ាងគឺ : ១-អង្គុយច្រហោងលើកដៃប្រណម្យសំពះចំពោះបុគ្គលដែល គួរគោរព គឺមាតា បិតា គ្រូឧបជ្ឈាយាចារ្យ និងព្រះពុទ្ធជាដើម, ២-អង្គុយលុតជង្គង់លើកដៃប្រណម្យសំពះចំពោះ បុគ្គល ដែលគួរគោរព គឺមាតាបិតា គ្រូឧបជ្ឈាយាចារ្យ និងព្រះពុទ្ធជាដើម និង៣-អង្គុយបត់ជើងលើក ដៃប្រណម្យសំពះចំពោះបុគ្គលដែលគួរគោរព គឺមាតា បិតា គ្រូឧបជ្ឈាយាចារ្យ និងព្រះពុទ្ធជាដើម ។ នៅក្នុងឥរិយាបថឈរដោយគោរពទាំង ៣យ៉ាង និងអង្គុយ ។

ដោយគោរពទាំង ៣យ៉ាងខាងលើនេះ គឺជាលក្ខណៈទន់ភ្លន់ ឱនលំទោន សុភាពរាបសា សំរាប់កតញ្ញូបុគ្គល ទាំង ៤ពួក គឺ១-បុត្រធីតា ត្រូវវន្ទាគោរពចំពោះមាតាបិតា, ២-សិស្សានុសិស្សត្រូវ វន្ទាគោរពចំពោះគ្រូ ឧបជ្ឈាយ៍, ៣-ប្រជារាស្ត្រត្រូវវន្ទាគោរពចំពោះព្រះមហាក្សត្រ ឬថ្នាក់ដឹកនាំ និង៤-ពុទ្ធបរិស័ទត្រូវវន្ទា គោរពចំពោះព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ។ ដោយឡែកឥរិយាបថអង្គុយពីរយ៉ាងទៀតគឺ ១-អង្គុយ ឬគង់លើកៅអី ដោយដាក់ព្រះបាទ ឬជើង កន្ទែកពីគ្នាបន្តិច ព្រះហស្ថ ឬដៃទាំងពីរដាក់លើជង្គង់ ឬលើ ភ្នាក់ដៃកៅអី ដងខ្លួនត្រង់ ពើងទ្រូងបន្តិច ព្រះភ័ក្ត្រ ឬមុខងើបមើលទៅឆ្ងាយ ។២-អង្គុយ ឬគង់ពែនភ្នែន លើអាសនៈ ឬធម្មាសនៈ ឬបល្ល័ង្ក ។ អង្គុយ ឬគង់ទាំងពីរយ៉ាងនេះ គឺជាលក្ខណៈរបស់ព្រះមហាក្សត្រស្តេច នាហ្មឺន សេដ្ឋី អ្នកមានអំណាច អ្នកចេះដឹង ឧកញ៉ា មហាមន្ត្រី អ្នកហ្មឹងហ្មាត់ អ្នកអង់អាចក្លាហាន អ្នកមាន គុណធម៌ សីលធម៌ និងអបចាយនធម៌បានដល់បុព្វការីជនទាំង ៤ពួក គឺ ១-មាតាបិតាគង់នៅចំពោះមុខកូន ប្រុសស្រី,
២-គ្រូឧបជ្ឈាយាចារ្យគង់នៅចំពោះមុខ សិស្សានុសិស្ស, ៣-ព្រះមហាក្សត្រ ឬថ្នាក់ដឹកនាំគង់នៅចំពោះមុខ ប្រជារាស្ត្រ និង៤-ព្រះពុទ្ធបដិមា ឬព្រះសង្ឃគង់នៅចំពោះមុខពុទ្ធបរិស័ទ ។
បុគ្គលទាំងអស់ដូចរៀបរាប់មកខាងលើនេះមិនគួរលើកព្រះហស្ថ ឬដៃសំពះអ្នកដែលមានឋានៈតូចទាបជាង ខ្លួនទេ ប៉ុន្តែគួរផ្សាយនូវព្រហ្មវិហារធម៌ចំពោះអ្នកតូចទាបឱ្យបានប្រពៃបំផុត ។ អាការៈទាំងនេះ ជាតួនាទី ដ៏សំខាន់សំរាប់បុព្វការីបុគ្គលទាំងឡាយ ដូចយើងទាំងអស់គ្នាបានដឹងហើយថា ទំនៀមទំលាប់នៃការទទួល ទានបាយក្នុងគ្រួសារខ្មែរ តាំងពីបុរាណកាលមកបើនៅចំពោះមុខមាតា បិតា គ្រូអាចារ្យ ព្រះសង្ឃ ឬអ្នកជា ធំក្នុងត្រកូលរៀមច្បង ពេលនោះកូនប្រុស ស្រី សិស្សានុសិស្ស ឬអ្នកដែលតូចជាងមិនអាចពែនភ្នែនហូប បាយនៅចំពោះមុខលោកទាំងនោះទេ ព្រោះនេះជាអំពើព្រហើនកោងកាចរំលោភបំពានតួនាទីរបស់បុគ្គល ដែលគួរគោរព ។ អ្នកណាហ៊ានធ្វើឥរិយាបថបែបនោះ គឺចាត់ទុកថា ជាអ្នកខ្វះការរៀនសូត្រ អប់រំនិង បទពិសោធន៍ក្នុងជីវិតទើបបានជាឆ្គងយ៉ាងនេះ សមនឹងសុភាសិត ដែលលោកប្រែពីភាសាសំស្ក្រឹតទុកមកថា

មានកូនមិនឱ្យកូនសូត្ររៀនចំណេះរបៀនការនានា មាតាលោកទុកជាវេរាបិតា ទុកជាសត្រូវធំ ។ កូនពេញរូបពាលពត់មិនឡើងហៅថា មិនថ្កើងក្នុងជំនុំប្រៀបដូចកុកគ្រោងចូលទៅទំកណ្តាលជំនុំនៃរាជហង្ស។ បើធ្វើយ៉ាងនេះ ឈ្មោះថា អ្នកតូចដណ្តើមតួនាទីអ្នកធំ មកប្រើដោយភាពងងឹតល្ងង់មិនដឹងបែបបទខុសត្រូវ ។ ចំណែកឯបុព្វការីបុគ្គលវិញ បើខ្វះសតិសម្បជញ្ញៈភ្លាត់ លើកដៃសំពះដោយខុសទំនងខុសតួនាទីខុសពេលវេលា ព្រោះអគតិធម៌ណាមួយចំពោះបុគ្គល ដែលមិនគួរសំពះនោះ វានឹងក្លាយទៅជា :

-អ្នកអង់អាចក្លាហាន ក្លាយជាកំសាក

-អ្នកម៉ឺងម៉ាត់ ក្លាយជាទន់ជ្រាយ

-អ្នកចេះដឹង ក្លាយជាអ្នកល្ងង់

-អ្នកនឹងន់ ក្លាយជារណេបរណប

-អ្នកខ្លាំងពូកែ ក្លាយជាទន់ខ្សោយ

-អ្នកមានសិរីសួស្តី ក្លាយជាអពមង្គល ។ល។

ហើយខុសអំពីមង្គល ៣៨ប្រការ ដែលព្រះពុទ្ធអង្គទ្រង់សំដែងទុកមកនូវមង្គលទី ២២ថា "គារវោច" សេចក្តីគោរពចំពោះបុគ្គលដែលគួរគោរពជាមង្គលដ៏ឧត្តម ។

ពន្យល់បន្ថែមចំពោះឥរិយាបថឈរ និងអង្គុយ ដែលមានអាការៈសំពះគឺ:

១-ឈរសំពះនៅចំពោះមុខបុព្វការី បុគ្គលទាំងឡាយមានឪពុក ម្តាយ គ្រូឧបជ្ឈាយាចារ្យ ព្រះសង្ឃ និងព្រះពុទ្ធជាដើម ត្រូវឈរឱនក្បាលបន្តិចលើកដៃប្រណម្យត្រឹមចុងច្រមុះ ហើយសូត្រថា (វន្ទាគ្រូ)

(បាលី)

ឧកាស.វន្ទាមិ ភន្តេ សព្វំ អបរាធំ ខមថ មេ ភន្តេ ។ល។

ប្រែថា

ខ្ញុំសូមគោរព បពិត្រលោកគ្រូដ៏ចំរើន សូមលោកគ្រូអត់នូវទោសកំហុសទាំងពួងដល់ខ្ញុំផង ។ល។

២-អង្គុយច្រហោងលើកដៃប្រណម្យត្រឹមប្រជុំចិញ្ចើមនៅចំពោះមុខបុព្វការីបុគ្គលទាំងឡាយ ហើយសូត្រថា :

(បាលី)

វន្ទាមិ ភន្តេ សព្វំ អបរាធំ ខមថ មេភន្តេ

ប្រែថា

បពិត្រ លោកគ្រូដ៏ចំរើន ខ្ញុំសូមថ្វាយបង្គំ សូមលោកអត់នូវទោសកំហុសទាំងពួងដល់ខ្ញុំផង ។

៣-អង្គុយលុតជង្គង់ប្រណម្យ ហើយក្រាបសំពះក្បាលដល់កន្ទេលចំពោះមុខបុព្វការីបុគ្គលទាំងឡាយ ហើយសូត្រថា :

(បាលី)

ឧកាស ទ្វារត្តយេន កតំ សព្វំ អបរាធំ ខមថ មេភន្តេ

ប្រែថា

សូមគោរពបពិត្រលោកគ្រូដ៏ចំរើន ទោសកំហុសឯណាមួយដែលខ្ញុំបានធ្វើហើយ ដោយទ្វារទាំងបី គឺកាយ វាចាចិត្ត សូមលោកអត់នូវទោសកំហុសនោះដល់ខ្ញុំផង ។

៤-អង្គុយបត់ជើង លើកដៃប្រណម្យ សំពះស្តាប់ធម្មទេសនាក្តី ស្តាប់លោកសូធ្យធមិក្តី ។

ប្រណម្យសំពះក្នុងតិរិយាបថឈរ និងអង្គុយទាំង៤បែបដូចពោលមកទាំងបាលី និងសំរាយខាងលើនេះ ជាគ្រឿងសំអាងក្នុងការគោរពតាមទំនៀមទំលាប់ប្រពៃណីខ្មែរ និង ប្រពៃណីព្រះពុទ្ធសាសនា ។

ពន្យល់បន្ថែមក្នុងតិរិយាបថអង្គុយពែន ភ្នែកដោយគោរព តែមិនឃើញមានសំពះ ហៅថា បញ្ចមុទ្រ

សំណួរដូចម្តេចដែលហៅថា បញ្ចមុទ្រ ចំលើយពាក្យថា បញ្ចមុទ្រ គឺជាភាសាបាលី មាន២បទ គឺបញ្ច ប្រែថា ៥(មួយបទ) និងមុទ្រះ ប្រែថា ត្រា ចិញ្ច្រៀន ចិញ្ច្រៀន ត្រា ពុម្ព ការបោះពុម្ព គ្រឿងសំគាល់ ។

រួមសព្ទទាំងពីរបញ្ចូលគ្នាមកបានជាបញ្ចមុទ្រះ ប្រែថា គ្រឿងសំគាល់ទាំង ៥យ៉ាង គឺ:

១-ភូមិមុទ្រ គង់ពែនភ្នែន ជើងស្តាំដាក់លើជើងឆ្វេង ព្រះហស្ថ ម្ខាងចង្អុរព្រះធរណី ព្រះហស្ថ ម្ខាងដាក់លើភ្នែន សំគាល់ថា ព្រះអង្គផ្ចាញ់មារ ។

២-វិត្តកមុទ្រះ គង់ពែនភ្នែនជើងស្តាំដាក់លើជើងឆ្វេង ព្រះហស្ថ ទាំងពីរដាក់លើភ្នែនទាំងពីរសំយុងទៅដីដូចគ្នាសំគាល់ថា ព្រះអង្គទ្រង់វិត្តកៈ ។

៣-អភយមុទ្រះ គង់ពែនភ្នែកជើងស្តាំ ដាក់លើជើងឆ្វេង ព្រះហស្ថ មួយដាក់លើភ្នែន ព្រះហស្ថ មួយលើកលាបែរទៅមុខ ឬលាព្រះហស្ថ ទាំងពីរសំគាល់ថា ព្រះអង្គទ្រង់ឱ្យអភ័យដល់សត្វ ។

៤-ធម្មចក្កមុទ្រះ គង់ពែនភ្នែនជើងស្តាំ លើជើងឆ្វេងព្រះហ្ថ ទាំងពីរបង្វិលចក្រ សំគាល់ថា ព្រះអង្គទ្រង់សំដែងធម្មចក្រា ។

៥-សមាធិម្មមុទ្រះ គង់ពែនភ្នែនជើងស្តាំលើជើងឆ្វេង ព្រះហស្ថ ស្តាំលើព្រហស្ថ ឆ្វេង ព្រះនេត្រទាំងគូបិទ

សំគាល់ថា ព្រះអង្គទ្រង់ធ្វើសមាធិ ។

យោងតាមសភាពជាក់ស្តែង ស្របនឹងប្រពៃណីទំនៀមទំលាប់ខ្មែរ ក៏ដូចជាប្រពៃណីព្រះពុទ្ធសាសនា បានបញ្ជាក់អំពីឥរិយាបថ ឈរ និងអង្គុយបុគ្គលដែលគួរសំពះ និងមិនគួរសំពះ ព្រមទាំងគ្រឿងសំគាល់ ៥យ៉ាង ហៅថា "បញ្ចមុទ្រៈ" ដែលបានពោលមកខាងលើនេះ ទើបទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំបាទសន្និដ្ឋានថា ព្រះបដិមាព្រះបាទជ័យវរ្ម័នទី ៧ មិនអាចគង់ពែនភ្នែន ហើយសំពះប្រណម្យទៅមុខ ដោយខុសតួនាទី និងខុសឫកពារនោះបានទេ ។ ប៉ុន្តែបើសិនជាអស់លោកអ្នកស្រាវជ្រាវរកឃើញ ព្រះហស្ត ពិតរបស់ព្រះអង្គស្ថិតនៅក្នុងទីណាមែននោះ គឺជាភ័ព្វវាសនារបស់ខ្មែរយើងប្រាកដណាស់ ឯការបកស្រាយ របស់ខ្ញុំទាំងប៉ុន្មានខាងលើចាត់ទុកជាមោឃៈចុះ ។ ម្យ៉ាងទៀតបើរកភស្តុតាងពិតមិនឃើញទេ គួរណាស់តែ សាងព្រះហស្ត របស់លោកតាមបែបអភយមុទ្រៈ លាព្រះហស្ត ទាំងពីរទៅមុខ ឬបែបសំដែងពន្យល់អ្វីមួយ ដោយប្រើព្រះហស្ត ទាំងពីរជួយបញ្ជាក់សេចក្តីឱ្យកាន់តែច្បាស់តាមទំរង់ធម្មចក្រមុទ្រៈ ។

ការចូលរួមផ្តល់មតិក្នុការសាងព្រះហស្ត និងព្រះសិរលាព្រះបាទជ័យវរ្ម័នទី ៧នេះ បើមានខុសឆ្គងដោយ ប្រការណាមួយនោះ សូមព្រះករុណា សម្តេចទ្រង់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី បណ្ឌិត បញ្ញវន្ត អ្នកសិក្សាស្រាវជ្រាវទាំងឡាយទ្រង់ព្រះមេត្តា និងមេត្តាព្រះរាជទានទោស និងអភ័យទោសដល់ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំបាទផង សូមអរព្រះគុណ និងអរគុណ ។

វ៉ោយ វិបុល

ផ្សព្វផ្សាយទូលំទូលាយដោយទូរទស្សន៍ Templenews
www.templenews.info

ប្រភពពតិមាន : សារពតិមានកោះសន្តិភាព ថ្ងៃអង្គារ៍ ទី០៨ ខែមេសា ព.ស.២៥៥១/គ.ស.២០០៨
Source: Koh Santepheap Newspaper Wednesday April 2, B.E.2551/C.E.2008